

ថ្ងៃមួយ យ៉េកនិងខេទីបានដឹករតនានិងមករាទៅភូមិស្វាយចេក
ទាំងពេលនោះមេឃកំពុងរលឹមព្រិចៗ។
នៅតាមផ្លូវ ពួកគេបានជិះកាត់រ៉ឺម៉កកង់បីជាច្រើន។
តើរ៉ឺម៉កកង់បីទាំងនោះមានពណ៌អ្វី?
ត្រូវហើយ! រ៉ឺម៉កកង់បីភាគច្រើនមានពណ៌ក្រហម។



បន្តិចក្រោយមក ពួកគេបានជិះកាត់លោកសង្ឃកំពុងនិមន្តតាមផ្លូវ ដោយក្នុងព្រះហត្ថកាន់ឆ័ត្រស្អាតៗគ្រប់ព្រះអង្គ។
តើលោកសង្ឃគ្រងស្បង់ពណ៌អ្វីដែរ?
ត្រូវហើយ! ទ្រង់គ្រងស្បង់ពណ៌ទឹកក្រូច។



ពួកគេបានជិះកាត់ដើមស្វាយដ៏ធំត្រឈឹងត្រឈៃមួយដែលមានផ្លែជាច្រើន។
តើផ្លែស្វាយមានពណ៌អ្វី?
ពេលដែលវាទុំហើយផ្អែម វាមានពណ៌លឿង។
តែរតនានិងមករាបែរជាចូលចិត្តញ៉ាំស្វាយពេលវានៅពណ៌បៃតងទៅវិញ។



ពួកគេបានជិះបត់តាមផ្លូវកោង ហើយមេឃក៏ចាប់ផ្ដើមរាំង។
តើមេឃមានពណ៌អ្វី?
ត្រូវហើយ! មេឃមានពណ៌ខៀវដូចរ៉ឺម៉កកង់បីរបស់យ៉េកអ៊ីចឹង។



ពួកគាត់បានជិះកាត់វាលមួយពោរពេញទៅដោយផ្កាអមតៈ។
នៅពេលយើងយកផ្កាអមតៈឆុងជាទឹកតែ តើវាចេញពណ៌អ្វី?
ទឹកតែនោះនឹងចេញពណ៌ខៀវស្វាយស្អាតណាស់។
ចុះពេលយើងដាក់ក្រូចឆ្មារចូលទៅ តើវាចេញពណ៌អ្វី?
វានឹងចេញពណ៌ស្វាយ។



មករាលើកដៃចង្អុលហើយស្រែក « មើលនោះទៅ! មានគេលាបពណ៌លើមេឃទំ! » ដោយមានឥន្ទធនូមួយបានបង្ហាញខ្លួននៅលើមេឃ។



រតនាក៏បាននិយាយ « នែ មករា! កុំចង្អុលទៅតន្ទធនូអ៊ីចឹង
ប្រយ័ត្នដាច់ម្រាមដៃទៅណា »។
មករាភ័យក៏ទម្លាក់ដៃរបស់ខ្លួនចុះភ្លាម។



ខេទីសួរ « ហេតុអ្វីទៅ? »
រតនាឆ្លើយ « ម្ដាយខ្ញុំតែងប្រាប់ថា បើយើងចង្អុលទៅឥន្ទធនូ
យើងនឹងដាច់ម្រាមដៃជាមិនខាន »។
មកវាក៏និយាយ « តែឥន្ទធនូស្អាតខ្លាំងណាស់។
បើសិនខ្ញុំអាចលាបពណ៌ឱ្យមេឃដូចអ៊ីចឹងដែរ មិនដឹងជាសប្បាយប៉ុណ្ណាទេ »។



យ៉េកព្រុខេទីនិយាយជាមួយក្មេងៗដូចនេះ គាត់ក៏បានឈប់រ៉ឺម៉កកង់បីបន្តិច
ដើម្បីមើលឥន្ទធនូទាំងអស់គ្នា ហើយយ៉េកក៏ចាប់ផ្តើមនិយាយបកស្រាយពីឥន្ទធនូ។




គាត់ចាប់ផ្ដើមបកស្រាយ « ឥន្ទធនូមើលទៅដូចជាគេលាបពណ៌លើមេឃអ៊ីចឹង តែតាមពិតវាគ្រាន់តែជាពន្លឺនៅលើមេឃប៉ុណ្ណោះ »។
គាត់បន្តទៀត « ទឹកភ្លៀងនិងពន្លឺថ្ងៃបូកចូលគ្នាបង្កើតបានជាពណ៌ដ៏ស្រស់ស្អាតទាំងនេះ »។
មករាក៏តប « ស្ដាប់ទៅដូចមានវេទមន្តលើមេឃអ៊ីចឹង »។



យ៉េកក៏សួរក្មេងៗ « តើអ្នកទាំងពីរស្គាល់ពណ៌ទាំងអស់ក្នុងឥន្ទធនូដែរឬទេ? »
រតនានិងមករាងើយមើលទៅមេឃ ហើយក៏ចាប់ផ្តើមរាប់ « ពណ៌ក្រហម ពណ៌ទឹកក្រូច
ពណ៌លឿង ពណ៌បៃតង ពណ៌ខៀវ ហើយពណ៌... »
ខេទីបន្ថែម « នៅមានពីរពណ៌ទៀតណា! »
យ៉េកក៏ឆ្លើយ « ត្រូវហើយ! នៅមានពណ៌ខៀវស្វាយនិងពណ៌ស្វាយទៀត »។



ខេទីក៏បានបន្តប្រាប់ពួកគេ « នៅប្រទេសអូស្ត្រាលី គេមានជំនឿតៗគ្នាថា ប្រសិនបើ យើងធ្វើដំណើរដល់ចុងឥន្ទធនូ នោះបំណងប្រាថ្នារបស់យើងនឹងក្លាយជាការពិត »។




ក្មេងៗក៏សួរទៅ ខេទីភ្លាម « ពិតមែនឬ? ចុះអ្នកធ្លាប់ទៅដល់ចុងឥន្ទធនូទេ? »



ខេទីក៏ឆ្លើយ « ខ្ញុំធ្លាប់ខំសាកទៅប៉ុន្មានដងដែរ តែរាល់ដងឱ្យតែមុនពេលខ្ញុំទៅដល់ចុង ឥន្ទធនូនោះ វាតែងបាត់ខ្លួនជានិច្ច។ នៅពេលយើងធ្វើដំណើរ ឥន្ទធនូហាក់បីដូចជា ធ្វើដំណើរតាមយើងអ៊ីចឹងដែរ។ ឥឡូវ នៅពេលខ្ញុំឃើញវា ខ្ញុំមិនដើរតាមវាទៀតទេ តែខ្ញុំចូលចិត្តអង្គុយមើលពណ៌របស់វាទៅវិញ »។



« តែខ្ញុំនៅតែចូលចិត្តប្រាប់បំណងប្រាថ្នារបស់ខ្ញុំទៅឥន្ទធនូអ៊ីចឹង... »
ដូច្នេះពួកគេទាំងបួននាក់ក៏នៅមើលឥន្ទធនូរហូតដល់វាបាត់ខ្លួន
ហើយពួកគេក៏បានប៉ងប្រាថ្នាក្នុងចិត្តប្រាប់ទៅឥន្ទធនូផងដែរ។




# តើនរណាជាអ្នកលាបពណ៌មេឃ?


អ្នកនិពន្ធ៖ TukTuk

អ្នកគំនូរ៖ ហ៊ិន ឆវិន


គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary